ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ០៨៤/២៣ រ.ប.ក

# របាយការណ៍ខែមីនា
# ស្ដីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅខែមេសា ឆ្នាំ២០២៣

## I. ស្ថានភាពទូទៅ

ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្ដាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ... ) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្ដាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្ដាប់ និងជឿការអូសទាញ ក្លួតករពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្ដៅ និងផ្ដល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្ដល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្ដល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ

ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌** បានរៀបចំបន្តពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី «អំពើពពោះជំនួស» និងច្បាប់ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស»។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

#### ២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «បត្យាប័ន» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការផ្ទេរទណ្ឌិត» ជាមួយសាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្រប៊ែលហ្សិក។

### ខ. ការបង្ការ ទប់ស្កាត់

#### ១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ១.១. ការអប់រំដោយផ្ទាល់

##### ១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២៣នេះ ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយស្តីពី ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព**" ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **៧០.០០៥**លើក មានអ្នកចូលរួមសរុបចំនួន **៣៣៩.៧៦៧**នាក់ ស្ត្រីចំនួន **១៧៦.០៥៦**នាក់ (ធៀបនឹងខែកុម្ភៈ មានចំនួន **៦៦២.២២១**នាក់ គឺមានការថយចុះចំនួន **៣២២.៤៥៤**នាក់ ស្មើនឹង៤៨,៦៩%) ក្នុងនោះ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យកិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៩៨ | ២៥.០២២ | ១២.១៣៨ | ៥៦០ | ១៧.០៣១ | ៨.៩៥៨ |
| | សរុប ក្រសួង ស្ថាប័ន | ៩៨ លើក | ២៥.០២២ នាក់ | ១២.១៣៨ នាក់ | ៥៦០ លើក | ១៧.០៣១ នាក់ | ៨.៩៥៨ នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៦២០ | ២០.៦២៣ | ១០.៣៣០ | ១.៣៧៤ | ១០២.១៩៨ | ៥២.១០១ |
| ៣ | ខេត្តបាត់ដំបង | ៨៩០ | ៣៦.៣៣៦ | ២០.០៩២ | ៧៥០ | ២៤.០៤៦ | ១៣.០៤០ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៥៦ | ៣០.៦២៦ | ១៥.៨៦១ | ១១៩ | ៥.៦៥៦ | ២.៨៦២ |
| ៥ | ខេត្តសៀមរាប | | | | | | |
| ៦ | ខេត្តកំពង់ឆ្នាំង | ៨២៦ | ២១.១២០ | ១១.១០៩ | ៤៣០ | ៩.១៣៥ | ៤.៧៣៩ |
| ៧ | ខេត្តកំពង់ចាម | | | | | | |
| ៨ | ខេត្តព្រះសីហនុ | ៣៦ | ២.៨១១ | ១.៣៩០ | ១ | ៤២៥ | ១០៥ |
| ៩ | ខេត្តព្រះវិហារ | | | | | | |
| ១០ | ខេត្តស្វាយរៀង | | | | ២៩២ | ១០.៥១២ | ៥.៩៤៥ |
| ១១ | ខេត្តប៉ៃលិន | ៧៣ | ១.៣៥៣ | ២៩៥ | ៣៦ | ១.៣៦៥ | ៣៤៣ |
| ១២ | ខេត្តកោះកុង | | | | ១០១ | ២.២៣៩ | ១.០៩៧ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ២៧០ | ២៦.៥១១ | ១៤.១៦៨ | ១៤ | ១.៦១១ | ៩៥១ |
| ១៥ | ខេត្តតាកែវ | | | | | | |
| ១៦ | ខេត្តក្រចេះ | ៥៩ | ១.១៤៧ | ៥៣២ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | | | | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៣.២៣០លើក | ១៤០.៥២៧នាក់ | ៧៣.៧៧៧នាក់ | ៣.១១៧លើក | ១៥៧.១៨៧នាក់ | ៨១.១៨៣នាក់ |
| | សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ៧.០០៥ លើក | | ចំនួនមនុស្សសរុប ៣៣៩.៧៦៧ នាក់ | | ចំនួនស្ត្រី ១៧៦.០៥៦ នាក់ | |

### ១.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ខេត្តព្រះសីហនុ៖** បានបញ្ជ្រាបអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកំលាំងពលកម្មកុមារ អំពើរំលោភបំពាន និងការធ្វើចំណាកស្រុកខុសច្បាប់ ក្នុងឱកាសពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១១ ឆ្នាំ២០២៣ ក្រោមប្រធានបទ "សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត" ក្រោមអធិបតីភាពឯកឧត្តម **តឹករ៉េត សំរេច** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តព្រះសីហនុ មានអ្នកចូលរួម **៩៣**នាក់ជាស្ត្រី។

- **ខេត្តកណ្តាល៖** មន្ទីរអប់រំយុវជន និងកីឡា បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅពេលគោរពទង់ជាតិរាល់ពេលព្រឹកថ្ងៃច័ន្ទ និងសន្និបាតបូកសរុបការងារប្រចាំឆ្នាំ ២០២២ និងទិសដៅបន្ត មានអ្នកចូលរួមសរុប **៤១៥**នាក់ ស្រី**១១៥**នាក់។
- **ខេត្តកំពង់ឆ្នាំង៖**
  - មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្ស តាមរយៈកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ដល់ប្រធានការិយាល័យអប់រំ រដ្ឋបាលក្រុង ស្រុកទាំង៨ និងសិស្សានុសិស្ស នៅក្នុងពេលគោរពទង់ជាតិមុនចូលរៀន និងនៅក្នុងមេរៀនសាលាផងដែរ។
  - ស្រុកទឹកផុសបានចុះផ្សព្វផ្សាយច្បាប់ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស តាមរយៈកិច្ចប្រជុំគណៈបញ្ជាការឯកភាព កិច្ចប្រជុំ គ.ក.ស.ក និងកិច្ចប្រជុំសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ចំនួន ០៣លើក មានអ្នកចូលសរុបចំនួន **៦៩**នាក់ ស្រី **១៥**នាក់។
  - ស្រុកសាមគ្គីមានជ័យ បានផ្សព្វផ្សាយស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ តាមរយៈកិច្ចប្រជុំ គ.ក.ស.ក ប្រចាំខែ មានអ្នកចូលរួម **២៧**នាក់ ស្រី **១០**នាក់។
- **ខេត្តបន្ទាយមានជ័យ៖**
  - **មន្ទីរអប់រំ យុវជន និងកីឡា** បាន៖ ១.បានប្រារព្ធទិវាអំណានថ្នាក់ខេត្តនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងបានបញ្ជ្រាបច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ មានអ្នកចូលរួម **២៨១**នាក់។ ២.រៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២១-២០២២ និងបានបញ្ជ្រាបការយល់ដឹងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ដល់លោកគ្រូ អ្នកគ្រូ សមាជិក សមាជិកា នៃអង្គសន្និបាតបានចំនួន **២៥៨**នាក់។ ៣.ជួបសំណេះសំណាលរវាងគណៈគ្រប់គ្រង និងមាតា បិតា អាណាព្យាបាលសិស្ស នៃសាលាចំណេះទូទៅអន្តរជាតិឌូវី សាខាខេត្តបន្ទាយមានជ័យ និងបានផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ដល់មាតាបិតា និងអាណាព្យាបាលសិស្សចំនួន **១៥៧**នាក់។
  - **មណ្ឌលធនធានពលករទេសន្តរប្រវេសន៍** បានចុះផ្សព្វផ្សាយតាមសហគមន៍ស្តីពី សុវត្ថិភាពចំណាកស្រុក បានចំនួន ៦ស្រុក( ស្វាយចេក ថ្មពួក ព្រះនេត្រព្រះ មង្គលបូរី ម៉ាឡៃ ភ្នំស្រុក) មានអ្នកចូលរួមសរុប **៧០១**នាក់ ស្រី**១៣៥**នាក់(អតីតពលករ **២១២**នាក់ ស្រី**១៨៦**នាក់)។
  - **អង្គការតំណក់ទឹក** បានរៀបចំការប្រជុំលើកកម្ពស់ការយល់ដឹង នៅភូមិអណ្តូងថ្មមាស សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត អប់រំដល់ក្រុមយុវជន និងគ្រួសារ ស្តីពី ចំណាកស្រុកប្រកបដោយសុវត្ថិភាព អ្នកចូលរួម ៤០នាក់ ស្រី**៣៩**នាក់។
  - **អង្គការអន្តរជាតិទេសន្តរប្រវេស៍(IOM)៖** បានធ្វើវគ្គតម្រង់ទិសណែនាំពលករត្រលប់មកពីប្រទេសថៃ និងប្រទេសម៉ាឡេស៊ី ស្តីពី ទេសន្តរប្រវេសន៍សុវត្ថិភាព ចំនួន៤០០នាក់ ស្រី២៦៨។

១.១.៤. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

- **ខេត្តបន្ទាយមានជ័យ៖**
  - **អង្គការកល្យាណមិត្ត** បានចុះធ្វើកម្មវិធីអប់រំផ្សព្វផ្សាយស្តីពី ការចំណាកស្រុកដោយសុវត្ថិភាព និងចែកសម្ភារៈដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន **៣៧៤**នាក់ ស្រី**២៥៦**នាក់។
  - **អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ៖** សហការជាមួយ រដ្ឋបាលស្រុកម៉ាឡៃ អូរជ្រៅ និង ក្រុងប៉ោយប៉ែត ដើម្បីរៀបចំផ្សព្វផ្សាយបន្តស្តីពីចំណាកស្រុកសុវត្ថិភាព និងការជួញដូរមនុស្សគ្រប់ទម្រង់ បានចំនួន១៣លើក មានអ្នកចូលរួម១៩៣នាក់ ស្រី១៤១នាក់។

### ១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមរយៈគេហទំព័រហ្វេសប៊ុក មានអ្នកចូលទស្សនាចំនួន ១.៦៥៨នាក់។

### ១.៣. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- ខេត្តបន្ទាយមានជ័យ៖ អង្គការសាម៉ារីតាន់ភឺស ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់មនុស្សចំនួន ៥៦៨នាក់(ស្រី២១០នាក់) កុមារ ៦៧នាក់(កុមារី ៣៥នាក់)។

### ១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ៖ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ខៀវ ចាន់រ៉ា** បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ដើម្បីចែករំលែកព័ត៌មាន គន្លឹះសំខាន់ៗជាចំណេះដឹង និងឆ្លើយតបនូវរាល់ចម្ងល់របស់អ្នកស្តាប់ ក្នុងកម្មវិធីសន្ទនាមតិ ជីវិតយើង សង្គមយើង នៅស្ថានីយ៍វិទ្យុជាតិកម្ពុជា និងវិទ្យុវត្តភ្នំ ដែលពិភាក្សានូវប្រធានស្តីពី សុវត្ថិភាពការធ្វើចំណាកស្រុកក្នុងស្រុករបស់កូនស្រី។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុក ទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ២២២.៨៣០នាក់ (ស្រី ៩៩.៧០២នាក់) អនីតិជន ៣.៤៤៦នាក់(ស្រី១.២៣២នាក់) ក្នុងនោះមាន៖
  - ស្របច្បាប់ ចំនួន ១៦៨.៦៦៥នាក់ (ស្រី៧៦.៥៧៩នាក់) អនីតិជន ៤១២នាក់(ស្រី១២២នាក់)
  - មិនស្របច្បាប់ចំនួន ៥៣.៤៩៤នាក់ (ស្រី២២.៨២៧នាក់) អនីតិជន ២.៩៣០នាក់ (ស្រី ១.០៨១នាក់)។
  - ដាច់ការទាក់ទងចំនួន ៦៧១នាក់ (ស្រី២៩៦នាក់) អនីតិជន ១០៤នាក់(ស្រី២៩)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯងពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១២៣.៦៤១នាក់ (ស្រី៥៨.៣៥០នាក់) អនីតិជន ៤៦៣នាក់ (ស្រី ១៧២នាក់)។
- **កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ ចំនួន ០១លើក មនុស្សចំនួន ០៦នាក់(ស្រី ០៣នាក់) បានធ្វើកិច្ចសន្យាអប់រំ ណែនាំរួចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ។

### ២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ តាកែវ កំពង់ចាម កែប សៀមរាប និងខេត្តស្វាយរៀង បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន ១៥២គោលដៅ មនុស្សចំនួន ១.២៥៩នាក់(ស្រី៧៦៨នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ បាត់ដំបង ព្រះវិហារ តាកែវ កោះកុង កំពតស្ទឹងត្រែង និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើស ចំនួន ២៧លើក។

### ២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

▪ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ បានចំនួន ១៨២នាក់(ស្រី១៥នាក់) មាន ១៤សញ្ជាតិ ហើយបានវាយតំលៃបញ្ជូនឱ្យក្រុមការងារច្រកចេញចូលតែមួយបានចំនួន ១៤៧នាក់(ស្រី១៩នាក់)។ បានប្រមូលព័ត៌មានពីសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងតាមរយៈទូរស័ព្ទ ចំនួន ០៤នាក់(ស្រី) មានសេចក្តីសុខធម្មតា។

### ៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- ខេត្តព្រះសីហនុះផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុបនិងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន ១.១៣៣នាក់។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

#### ១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៩ករណី/១៦ករណី (ធៀបនឹងខែកុម្ភៈ កើន០៣ករណី ស្មើនឹង ១៨,៧៥%) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ២១នាក់ (ស្រី០៤នាក់) ជនសង្ស័យជាអនីតិជន០២នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ១៥៨នាក់(ស្រី៦៤នាក់) មានៈ អាយុក្រោម១៥ឆ្នាំ ១៤នាក់ អាយុ១៥-១៧ឆ្នាំ ០៥នាក់ និងអាយុ១៨ឆ្នាំឡើង ១៣៩នាក់ (ប្រគល់ឱ្យសង្គមកិច្ច ១៧នាក់ និងប្រគល់ឱ្យគ្រួសារ ១៤១នាក់) ក្នុងនោះចែកជាៈ

❖ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៣ករណី/០២ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៣៦នាក់(ស្រី៤២នាក់) មានៈ អាយុ១៥-១៧ឆ្នាំ ០២នាក់ និងអាយុ១៨ឆ្នាំឡើង ១៣៤នាក់ (ប្រគល់ឱ្យសង្គមកិច្ច ១១នាក់ និងប្រគល់ឱ្យគ្រួសារ ១២៥នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០១ | ០១ (០១) | ០១ |
| -ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០២ | ១៣៥(៤១) | ០២ |
| *សរុប* | *០៣ ករណី* | *១៣៦ (៤២) នាក់* | *០៣ នាក់* |

❖ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៦ករណី/១៤ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៨នាក់(ស្រី០៤នាក់) ជនសង្ស័យជាអនីតិជន ០២នាក់។ សង្គ្រោះជនរងគ្រោះចំនួន ២២នាក់(ស្រី២២នាក់) មានៈ អាយុក្រោម១៥ឆ្នាំ ១៤នាក់ អាយុ១៥-១៧ឆ្នាំ០៣នាក់ និងអាយុ១៨ឆ្នាំឡើង០៥នាក់ (ប្រគល់ឱ្យសង្គមកិច្ច០៦នាក់ ប្រគល់ឱ្យគ្រួសារ១៦នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ (ស្រី) | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០២ | ០៦ (០៦) | ០៣ |
| -បទល្មើសទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៣ (០៣) | ០២ |
| -រូបភាពនិងសម្ភារៈអាសអាភាស | ០២ | ០២ (០២) | ០២ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៦ | ០៦ (០៦) | ០៦(អនី.១) |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ (០៥) | ០៥(អនី.១) |
| *សរុប* | *១៦ ករណី* | *២២ (២២) នាក់* | *១៨ នាក់ (អនី.២)* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន **១៧**នាក់(ស្រី) មកពីប្រទេសចិន ១៦នាក់ និងប្រទេសម៉ាឡេស៊ី ០១នាក់ ក្នុងនោះករណីរងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ១៦នាក់ និងកេងប្រវ័ញ្ចប្រាក់ឈ្នួល ០១នាក់។
  - **ខេត្តកោះកុងៈ** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០២លើក មនុស្សចំនួន ០២នាក់(ស្រី០១នាក់)។
  - **ខេត្តបន្ទាយមានជ័យៈ** បានទទួលសម្ភាសន៍ពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនត្រឡប់មកវិញ ចំនួន **៣៧**លើក មានមនុស្ស **៧២៩**នាក់(ស្រី**២៦២**នាក់ កុមារា **៦៧**នាក់ កុមារី **០៧**នាក់)។
  - **ខេត្តស្វាយរៀងៈ** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរវៀតណាមបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០១លើក មនុស្សចំនួន **១២**នាក់(ប្រុស០១នាក់ ស្រី០៣នាក់ កុមារ ០៦នាក់ កុមារី០២នាក់)។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាល

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជៈ** បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ជូនដល់កងកម្លាំងរក្សាសន្តិភាព នៃកងអនុសេនាធំវិស្វកម្មសំណង់លេខ៤២៣ មុនពេលចេញបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ(អ.ស.ប) នៅខេត្តកំពង់ស្ពឺ មានសិក្ខាកាមចូលរួម ចំនួន **៥១**នាក់ ស្រី០៥នាក់ ។

- **ខេត្តបន្ទាយមានជ័យៈ** គ.ខ.ប.ជ សហការជាមួយអង្គការ IOM បើកវគ្គបណ្តុះបណ្តាលស្តីពី«ការគូសផែនទីប្រជាជនបំលាស់ទីចល័ត» ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង់ប្រជាជនបំលាស់ទី និងការគ្រប់គ្រងជំងឺឆ្លងផ្សេងៗ មានអ្នកចូលរួម **២៩**នាក់ ស្រី **១៧**នាក់។

- **ខេត្តក្រចេះៈ** ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការ មេត្រីអន្តរជាតិ(AIM SWAT) បើកវគ្គបណ្តុះបណ្តាលស្តីពី ការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស ការកំណត់អត្តសញ្ញាណជនរងគ្រោះ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់មន្ត្រីជំនាញពាក់ព័ន្ធទាំង៦ក្រុង-ស្រុក ចំនួន **៣២**នាក់ ស្រី**១០**នាក់។

- **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រុមហ៊ុនចំនួន៦ បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាព ការងារ និងការជួយសង្គ្រោះបឋម ចំនួន០៦វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន **១៣៩**នាក់ ស្រី **៨២**នាក់។

**២. សិក្ខាសាលា**

- **ខេត្តបន្ទាយមានជ័យ៖** គ.ខ.ប.ជ សហការជាមួយ រដ្ឋបាលខេត្ត មន្ទីរធម្មការនិងសាសនា និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) រៀបចំសិក្ខាសាលាស្តីពី កិច្ចសន្ទនាអន្តរជំនឿ ដើម្បីសុខដុមនីយកម្មសាសនានៅកម្ពុជា ក្រោមប្រធានបទ «សាសនិកចូលរួមប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប» មានអ្នកចូលរួមសរុប **១០៧**នាក់ ស្រី**៣៥**នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

**១. ក្នុងប្រជុំក្នុងប្រទេស**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** បានរៀបចំសន្និបាតផ្សព្វផ្សាយ របាយការណ៍ជាតិឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅវិទ្យាស្ថានជាតិអប់រំ មានអ្នកចូលរួមសរុប **៣៦០**នាក់ ស្រី**១៩៨**នាក់។

  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងវិភាគអំពីស្ថានភាពអាជីវកម្មផ្លូវភេទលើកុមារ របស់អង្គការ Terre des Hommes និងសហការជាមួយអង្គការ UNFPA បានចុះទស្សនកិច្ចត្រួតពិនិត្យការងារទេសន្តប្រវេសន៍ និងនាំយកឧបករណ៍សម្ភារៈសោតទស្សន៍ (Audio and Visual Devices Equipment) ទៅប្រគល់ជូនអាជ្ញាធរតាមច្រកព្រំដែន នៃខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៤៣**លើក មានអ្នកចូលរួមសរុប **១.២០៤**នាក់(ស្រី **៤៨៥**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **១៣**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត **៣០**លើក។**(ឧបសម្ព័ន្ធ១)**

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក. ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។

- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ខ. ចំណុចខ្វះខាត ឬភាពប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។

**គ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមីនា ឆ្នាំ ២០២៣

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការជេកហូតសរីរាង្គជួញដូរ ការកេ់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.........ខែ.........ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"**ដើម្បីគោរពជូនជាសេចក្តីរាយការណ៍**"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**-ដើម្បីជូនជ្រាប-**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ( សរុបចំនួន ៤៣លើក) មនុស្សចំនួន ១.២០៤នាក់ (ស្រី ៤៨៥នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ជាអធិបតីបើកកិច្ចប្រជុំបច្ចេកទេសថ្នាក់ជាតិស្តី ពីការពិនិត្យកែសម្រួលផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ នៅសណ្ឋាគារ SUN & MOON រាជធានីភ្នំពេញ ដែលរៀបចំដោយអង្គការ IOM មានអ្នកចូលរួមចំនួន **៤៧**នាក់ ស្រី **១១**នាក់។<br>- ជាអធិបតីកិច្ចប្រជុំពិនិត្យវឌ្ឍនភាព នៃការគ្រប់គ្រងមណ្ឌលទទួលពលករកំរៀង នៅសាលាស្រុកកំរៀង ខេត្តបាត់ដំបង មានអ្នកចូលរួម ៤៣នាក់ ស្រី**១៣**នាក់។<br>- ចុះសួរសុខទុក្ខ ពលករដែលត្រលប់មកស្រុកកំណើតវិញ នៅមណ្ឌលទទួលពលករស្រុកកំរៀង ខេត្តបាត់ដំបង អមដំណើរដោយលោកជំទាវ អគ្គលេខាធិការ។<br>- ដឹកនាំប្រតិភូមកពីអង្គការសហប្រជាជាតិ UNFPA ចុះទៅជួបសំណេះសំណាលជាមួយក្រុមការងារ នៅច្រកទ្វារព្រំដែនអន្តរជាតិដូង មណ្ឌលសំចតប៉ោយប៉ែត និងរដ្ឋបាលខេត្តឧត្តរមានជ័យ ព្រមទាំងបានប្រគល់ជូននូវកញ្ចប់មនុស្សធម៌ជូនផងដែរ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ចូលរួមកិច្ចប្រជុំបច្ចេកទេសថ្នាក់ជាតិ ស្តីពីការពិនិត្យកែសម្រួលផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពរៀបរយ និងស្របច្បាប់ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសណ្ឋាគារ SUN & MOON រាជធានីភ្នំពេញ។<br>- អមដំណើរ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំពិនិត្យវឌ្ឍនភាព នៃការគ្រប់គ្រងមណ្ឌលទទួលពលករកំរៀង នៅសាលាស្រុកកំរៀង ខេត្តបាត់ដំបង។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ០៩ច្បាប់ លិខិតចូល ១០ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ០៤ច្បាប់ លិខិតចូល ២៣ច្បាប់។<br>- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន ៩២ច្បាប់។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ២២សកម្មភាព។<br>- អាប់ឡូតឯកសារចូលបណ្ណាល័យវីគីបានចំនួន ០៩សច្បាប់។ |

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

  - បានអមដំណើរលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ.បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីបញ្ចប់ផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣-២០២៥ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ ដែលរៀបចំដោយអង្គការ IOM UN migration ក្រោមអធិបតីភាព ឯកឧត្តម សាស្ត្រាចារ្យ **ស៊ា ហួង** រដ្ឋលេខាធិការក្រសួងសុខាភិបាល នៅសណ្ឋាគារអិលប៊ីអិនអាស៊ាន ខេត្តកំពង់ចាម មានអ្នកចូលរួម **២៧**នាក់ ស្រី **០៧**នាក់។

- **ក្រុមជំនួយកិច្ចការយុត្តិធម៌**

  - ឯកឧត្តម ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង បានចូលរួម៖ **១.**កិច្ចប្រជុំពិភាក្សាស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនិងវិភាគអំពីស្ថានភាពអាជីវកម្មផ្លូវភេទលើកុមារ និងដើម្បីសុំគោលការណ៍សិក្សាស្រាវជ្រាវបន្ត របស់អង្គការ Terre des Hommes ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ **២.**កិច្ចប្រជុំពិភាក្សាដើម្បីផ្តល់ធាតុចូលស្តីពី ការពង្រឹងការការពារ និងផ្តល់សេវាដល់ជនរងគ្រោះនៅកម្ពុជា សម្រាប់ជាមូលដ្ឋានក្នុងការផ្តល់ជាការគាំទ្រការអនុវត្តគម្រោង ក្រោមអធិបតីភាពលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

  - លោកជំទាវ ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយលើការវិភាគស្ថានភាពកុមារ និងក្មេងជំទង់នៅកម្ពុជា ដែលបានរៀបចំដោយអង្គការយូនីសេហ្វ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ មានអ្នកចូលរួមចំនួន **៧០**នាក់ ព្រមទាំងមានការចូលរួម តាមប្រព័ន្ធអនឡាញមួយចំនួនទៀត។
  - លោកឧត្តមសេនីយ៍ត្រី អនុប្រធានក្រុមជំនួយកិច្ចការ បានចូលរួមកិច្ចប្រជុំពិភាក្សាដើម្បីផ្តល់ធាតុចូលស្តីពី ការពង្រឹងការការពារ និងផ្តល់សេវាដល់ជនរងគ្រោះនៅកម្ពុជា សម្រាប់ជាមូលដ្ឋានក្នុងការផ្តល់ការគាំទ្រការអនុវត្តគម្រោង ក្រោមអធិបតីភាព **លោកជំទាវ អគ្គលេខាធិការគ.ជ.ប.ជ**។

- **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**

  - អនុប្រធានក្រុមជំនួយកិច្ចការ បានចូលរួមសិក្ខាសាលាត្រីភាគី-បូក ស្តីពីការពិនិត្យឡើងវិញលើការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការ ILO ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ុ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារភ្នំពេញ។
  - ដោយមានកិច្ចសហការជាមួយអង្គការ UNFPA ឯកឧត្តមអគ្គលេខាធិការរង តំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំក្រុមការងារ នាំយកឧបករណ៍សម្ភារសោតទស្សន៍(Audio and Visual Devices/Equipment)មានដូចជា ទូរទស្សន៍ ជើងទប់លំនឹង ឧបករណ៍បំពងសំឡេង ដើម្បីផ្តល់ជូន ការិយាល័យច្រកចេញចូលតែមួយខេត្តឧត្តរមានជ័យ ២ឈុត ការិយាល័យច្រកចេញចូលតែមួយខេត្តបន្ទាយមានជ័យ ១ឈុត ការិយាល័យច្រកចេញចូលតែមួយខេត្តបាត់ដំបង ២ឈុត ច្រកតំបន់អូរអន្លក់ ១ឈុត និងច្រកព្រំដែនអន្តរជាតិដូង ១ឈុត។
  - អមដំណើរលោកជំទាវ **អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ** ធ្វើបឋកថាស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ជូនដល់សិក្ខាកាមវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាលកម្រិត១ និងកម្រិត២ ជំនាន់ទី៣ នៅបណ្ឌិត្យសភានគរបាលកម្ពុជា។

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម ឧត្តមសេនីយ៍ត្រី អគ្គលេខាធិការរង បានអញ្ជើញ៖ **១.**ធ្វើជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម មានសិក្ខាកាមចូលរួម **៥៦**នាក់ ស្រី ០៤នាក់។ **២.**ចូលរួមកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារខមមីត ក្នុងនាមតំណាងលោកជំទាវ **វ៉ន សិរីលក្ខិណា** អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាពលោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី មានអ្នកចូលរួម **៤៣**នាក់ ស្រី**១៩**នាក់។ **៣.**កិច្ចប្រជុំពិភាក្សាដើម្បីផ្តល់ធាតុចូលស្តីពី ការពង្រឹងការការពារ និងផ្តល់សេវាដល់ជនរងគ្រោះនៅកម្ពុជា ក្រោមអធិបតីភាព **លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ** នៅសាលប្រជុំ គ.ជ.ប.ជ។ **៤.**អមដំណើរលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ធ្វើបឋកថាស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ជូនដល់សិក្ខាកាមវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាលកម្រិត១ និងកម្រិត២ ជំនាន់ទី៣ នៅបណ្ឌិត្យសភានគរបាលកម្ពុជា។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៣០លើក អ្នកចូលរួមសរុបចំនួន ៩១៨នាក់(ស្រី ៤៣០នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ ប្រជុំបូកសរុបរបាយការណ៍ប្រចាំខែ និងត្រីមាសទី១ ចំនួន ០១លើក មានអ្នកចូលរួម **៥៤**នាក់ ស្រី**៣៥**នាក់។<br>- បានចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យការងារសម្អាតប្រាក់ និងពង្រីកការស៊ើបអង្កេតស្រាវជ្រាវបទល្មើសសម្អាតប្រាក់ដែលបានមកពីបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងទម្រង់ផ្សេងៗ តាមប្រព័ន្ធអនឡាញ ០១លើក។<br>- ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយប្រតិភូទីភ្នាក់ងារអន្តរជាតិប្រទេសស៊ុយអែត(SIDA) និងអង្គការ UNICEF ដើម្បីស្វែងយល់ពីការអនុវត្តសកម្មភាពកិច្ចការពារកុមារ។<br>- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ របស់ គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** នៅវិទ្យាស្ថានជាតិអប់រំ។<br>- បានចូលរួមកម្មវិធីផ្សព្វផ្សាយផែនការអនុវត្តយុទ្ធសាស្ត្រវិស័យកិច្ចការពារកុមារឆ្នាំ ២០២២-២០២៦ និងគោលការណ៍ណែនាំស្តីពី ការសមាហរណកម្ម ការបង្វែរកន្លែងថែទាំ និងបិទកន្លែងថែទាំកុមារ ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារភ្នំពេញ។<br>- ក្រុមការងារក្រុង-ស្រុក ប្រជុំប្រចាំខែ ចំនួន **០៧**លើក អ្នកចូលរួម **១៩២**នាក់ ស្រី**១០៥**នាក់។ |
| **ខេត្តកោះកុង** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ របស់ គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** នៅវិទ្យាស្ថានជាតិអប់រំ។ |
| **ខេត្តបន្ទាយមានជ័យ** | - លោកស្រី ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួម៖ **១.**សម្របសម្រួលប្រគល់ និងទទួលសម្ភារៈឧបករណ៍សោតទស្សន៍ មានដូចជា៖ ទូរស្សន៍ បន្ទះឧបករណ៍បំពងសំលេង ជើងទម្រទូរស្សន៍ចល័ត របស់គម្រោងកម្មវិធីរួមរបស់អង្គការសហប្រជាជាតិស្តីពី«RMWs គាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការឆ្លើយតបសុខភាពព្រំដែន ដើម្បីទប់ស្កាត់ការរីករាតត្បាតនៃជំងឺកូវីដ១៩ និងបំពេញតម្រូវការបន្ទាន់នៃពលករចំណាកស្រុកដែលត្រឡប់មកពីបរទេសវិញ» មានអ្នកចូលរួម **១៦**នាក់ ស្រី**០៧**នាក់។ **២.**សិក្ខាសាលាកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ថៃ ស្តីពីការទប់ស្កាត់ នៃការរីករាលដាលនៃជំងឺឆ្លង និងការគ្រប់គ្រងអនាម័យនៅច្រកព្រំដែនលើកទី២(ខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ) ការសម្របសម្រួលឆ្លងព្រំដែន ការគ្រប់គ្រងលំហូរដ៏ធំនៃជនចំណាកស្រុកត្រឡប់ទៅធ្វើការក្នុងប្រទេសថៃវិញ និងការគ្រប់គ្រងអំពើជួញដូរមនុស្សគ្រប់ទម្រង់ មានអ្នកចូលរួម **៥៣**នាក់ ស្រី**១១**នាក់។ |

| | |
|---|---|
| **ខេត្តស្វាយរៀង** | - បានអមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចុះពិនិត្យទីតាំងដីចំការកូនស្នាច់ ដែលស្ថិតនៅភូមិថ្នាញ សង្កាត់បាទី ក្រុងបាវិត សម្រាប់សាងសង់មណ្ឌលសំចត ។<br>- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ របស់ គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** នៅវិទ្យាស្ថានជាតិអប់រំ។<br>- បានរៀបចំកិច្ចប្រជុំស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ និងទិសដៅបន្ត មានអ្នកចូលរួមចំនួន **៥៧**នាក់ ស្រី **២៤**នាក់។ |
| **ខេត្តបាត់ដំបង** | - បានទទួលជួបសម្ភាសជាមួយអង្គការសាម៉ារីតាន់កឺសសង្គ្រោះអន្តរជាតិ ដើម្បីសិក្សាស្វែងយល់នូវព័ត៌មានសំខាន់ៗ សម្រាប់ជាធាតុចូលក្នុងការធ្វើយុទ្ធសាស្ត្រ ៥ ឆ្នាំ (២០២៣-២០២៨) របស់អង្គការ និងធ្វើបទបង្ហាញពីគម្រោងថ្មី"យុវជនសម្រាប់សហគមន៍ នៅសាលាខេត្តបាត់ដំបង ។<br>- បានចូលរួមកម្មវិធីប្រគល់-ទទួលយកឧបករណ៍សម្ភារៈសោតទស្សន៍ (Audio and Visual devices/ equipment) នៅសាលាខេត្ត និងនៅច្រកទ្វារព្រំដែនក្នុងខេត្តបាត់ដំបង ។<br>- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ របស់ គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** នៅវិទ្យាស្ថានជាតិអប់រំ។<br>- បានចូលរួមកិច្ចប្រជុំពិនិត្យវឌ្ឍនភាពនៃការគ្រប់គ្រងមណ្ឌលទទួលពលករកំរៀងក្នុងឆ្នាំ២០២២ និងទិសដៅបន្តឆ្នាំ២០២៣ នៅសាលាស្រុកកំរៀង។<br>- បានទទួលអំណោយរបស់អង្គការ UNFPA ជាសម្ភារ: Dignity Kits នៅមណ្ឌលទទួលពលករកំរៀង ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីគោលនយោបាយកិច្ចការពារកុមារ/ការរំលោភបំពានលើកុមារ មានអ្នកចូលរួម **៣៦**នាក់ ស្រី **១៥**នាក់ នៅសាលាស្រុកសំឡូត។<br>- **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានផ្សព្វផ្សាយអំពីការចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងពលករបញ្ជូនត្រឡប់ពីប្រទេសថៃចំនួន **០៣**លើក នៅឃុំតាក្រៃ និងមជ្ឈមណ្ឌលទទួលពលកំរៀង ដែលមានអ្នកចូលរួមចំនួន **៥១០**នាក់ ស្រី **២៣៣**នាក់ ។ |
| **ប៉ៃលិន** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ របស់ គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** នៅវិទ្យាស្ថានជាតិអប់រំ។ |
| **ស្ទឹងត្រែង** | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ របស់ គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** នៅវិទ្យាស្ថានជាតិអប់រំ។ |
| **ខេត្តកំពង់ធំ** | - ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកម្មវិធី យុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិត នៅវិទ្យាស្ថានបច្ចេកវិទ្យា(តិចណូ) ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ០១លើក។ |
| **ខេត្តកំពង់ឆ្នាំង** | - ប្រធានលេខាធិការដ្ឋាន បានដឹកនាំកិច្ចប្រជុំប្រចាំខែ ០១លើក។ |